ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ ៦២៧៤ ឧស្ម.ធរ.អបហ.

រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែ ធ្នូ ឆ្នាំ ២០០៧

# អាជ្ញាប័ណ្ណស្វែងរុករក

(លើកទី២)

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការគ្រប់គ្រង និង ការធ្វើអាជីវកម្មធនធានរ៉ែ ។
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញកិច្ចព្រមព្រៀងសិក្សាស្រាវជ្រាវ និងធ្វើអាជីវកម្មរ៉ែលោហៈនៅតំបន់មេសំ ស្រុកកែវសីមា ខេត្តមណ្ឌលគីរី ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០៤ រវាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រុមហ៊ុន JINQU MINERAL Co., Ltd ។
- បានឃើញសេចក្តីកែតម្រូវលេខ ០០១ នៃកិច្ចព្រមព្រៀងស្តីពីការសិក្សាស្រាវជ្រាវ និងធ្វើអាជីវកម្មរ៉ែលោហៈនៅតំបន់មេសំ ស្រុកកែវសីមា ខេត្តមណ្ឌលគីរី ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០០៥ ។
- បានឃើញអាជ្ញាប័ណ្ណស្វែងរុករកលេខ:២៣៣ ឧរថ.ធរ.អប ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០០៥ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។
- បានឃើញលិខិតស្នើសុំពន្យាបន្តអាជ្ញាប័ណ្ណសិក្សាស្រាវជ្រាវរ៉ែលោហៈ នៅតំបន់មេសំ ស្រុកកែវសីមា ខេត្តមណ្ឌលគីរី របស់ក្រុមហ៊ុន ZHONG XIN INDUSTRIAL INVESTMENT (CAMBODIA) Co., Ltd ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៧ ។
- បានឃើញសំណើសុំកាត់បន្ថយផ្ទៃក្រឡាដីសម្បទានសិក្សាស្រាវជ្រាវ និង ធ្វើអាជីវកម្មរ៉ែលោហៈ នៅតំបន់មេសំ ស្រុកកែវសីមា ខេត្តមណ្ឌលគីរី របស់ក្រុមហ៊ុន ZHONG XIN INDUSTRIAL INVESTMENT (CAMBODIA) Co., Ltd ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៧ ។

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ១៤១ ទូរសារ: (៨៥៥) ២៣ ៤២៨ ២៦៣
45 Preah Norodom Boulivard, Khan Daun Penh, Phone: (855) 23 211 141 Fax: (855) 23 428 263

<u>សំរេច</u>

**ប្រការ១:** អនុញ្ញាតអោយក្រុមហ៊ុនZHONG XIN INDUSTRIAL INVESTMENT (CAMBODIA) Co., Ltd មានអាសយដ្ឋាននៅផ្ទះលេខ ២០ ផ្លូវលេខ ២៨៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ធ្វើការសិក្សាស្រាវជ្រាវរ៉ែលោហៈបន្តនៅតំបន់មេសំ ស្រុកកែវសីមា ខេត្តមណ្ឌលគិរី លើផ្ទៃដីទំហំ ១៩.៦ ( ដប់ប្រាំបួនក្បៀសប្រាំមួយ ) គីឡូម៉ែត្រក្រឡា ដែលមានកូអ័រដោណេដូចតទៅ :

| ចំណុច | អាប់ស៊ីស | អ័រដោណេ | ចំណុច | អាប់ស៊ីស | អ័រដោណេ |
|---|---|---|---|---|---|
| $A_1$ | $7\ 01^{500}$ | $13\ 97^{000}$ | C | $7\ 06^{500}$ | $13\ 93^{255}$ |
| $B_1$ | $7\ 06^{500}$ | $13\ 97^{000}$ | D | $7\ 01^{500}$ | $13\ 93^{255}$ |

**ប្រការ២:** ក្រុមហ៊ុនត្រូវដំណើរការសិក្សាស្រាវជ្រាវរ៉ែ លើផ្ទៃដីដែលបានកំណត់ខាងលើ ដោយអនុវត្តទៅតាមផែនការឆ្នាំ និងកម្មវិធីការងាររបស់ខ្លួនដោយធានាអនុវត្តតាមបទដ្ឋានបច្ចេកទេស ក្នុងការសិក្សាស្រាវជ្រាវរុករករ៉ែ ។

**ប្រការ៣:** អាជ្ញាប័ណ្ណនេះមានសុពលភាពរយៈពេល ០២ (ពីរ) ឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខា ។ មុនផុតកំណត់ ៣០ថ្ងៃ ក្រុមហ៊ុនត្រូវដាក់ពាក្យសុំពន្យារអាជ្ញាប័ណ្ណស្វែងរុករករ៉ែបន្តជាថ្មី ។

**ប្រការ៤:** ក្នុងករណីប្រព្រឹត្តល្មើសលើលក្ខខណ្ឌនៃកិច្ចព្រមព្រៀងចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០៤ អាជ្ញាប័ណ្ណនេះនឹងត្រូវព្យួរទុក ឬ ដកហូត ឬ ត្រូវពិន័យទៅតាមច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ។

**ប្រការ៥:** អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានរ៉ែ អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តមណ្ឌលគិរី និង ប្រធានក្រុមហ៊ុន ZHONG XIN INDUSTRIAL INVESTMENT (CAMBODIA) Co., Ltd ត្រូវទទួលអនុវត្តអាជ្ញាប័ណ្ណនេះតាមភារៈកិច្ចរៀងៗខ្លួន ។

**ប្រការ៦:** អាជ្ញាប័ណ្ណនេះមានសុពលភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ស៊ុយ_សែម

**<u>ចំលងជូន</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងបរិស្ថាន
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- សាលាខេត្តមណ្ឌលគិរី
- សាលាស្រុកកែវសីមា
- ដូចប្រការ៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ